# សេចក្តីផ្តើមសន្និសីទអាស៊ានស្តីពីកិច្ចការមុខងារសាធារណៈ (ACCSM)

វិស័យមុខងារសាធារណៈគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍក្នុងរដ្ឋជាសមាជិកអាស៊ាននីមួយៗ និងកិច្ចសហប្រតិបត្តិការតំបន់។ ការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការក្នុងតំបន់ប្រកបដោយប្រសិទ្ធិភាព ប្រសិទ្ធផល គណនេយ្យភាពនៃប្រព័ន្ធមុខងារសាធារណៈនិងអភិបាលកិច្ចល្អ នឹងកំពុងចូលរួមចំណែកដើម្បីសម្រេចបាននូវចក្ខុវិស័យអាស៊ាន ២០២៥ ដែលក្លាយជាសហគមន៍ដែលមានភាពស្អិតរមួតខាងនយោបាយ សមាហរណកម្មសេដ្ឋកិច្ច គណនេយ្យភាពសង្គម និងផ្អែកលើគោលការច្បាប់ពិតប្រាកដ ការតម្រង់ទៅរកប្រជាជន និងការយកប្រជាជនជាស្នូល។

កិច្ចសហប្រតិបត្តិការវិស័យមុខងារសាធារណៈក្នុងចំណោមប្រទេសជាសមាជិកអាស៊ានបានចាប់ផ្តើមក្នុងឆ្នាំ១៩៨០ ក្នុងនាមជាសន្និសីទអាស៊ានស្តីពីកំណែទម្រង់មុខងារសាធារណៈ (ACRCS) ។ បន្ទាប់មក សន្និសីទអាស៊ានស្តីពីកិច្ចការមុខងារសាធារណៈ(ACCSM) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨១ ដើម្បីជម្រុញកម្រិតកិច្ចសហប្រតិបត្តិការក្នុងវិស័យមុខងារសារធារណៈអាស៊ានកាន់តែខ្លាំង។ ក្នុងអំឡុងពេលនេះ សមាជិកនៃ ACCSM បានពង្រីកដោយបញ្ចូលរដ្ឋជាសមាជិកអាស៊ានទាំង១០ នៅក្នុងឆ្នាំ ១៩៩៩។

ចាប់តាំងពីការបង្កើត ACCSM បានបន្តជា វេទិកាផ្លាស់ប្តូរព័ត៌មាន នវានុវត្តន៍ និងឧត្តមានុវត្តន៍ ក្នុងការគ្រប់គ្រងវិស័យសាធារណៈក្នុងអាស៊ាន។ ACCSM ក៏បន្តលើកកម្ពស់ប្រសិទ្ធិភាពកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមករវាងសមាជិកអាស៊ាន ការកសាងសមត្ថភាពដែលគាំទ្រដល់ការ កាត់បន្ថយគំលាតនៃការអភិវឌ្ឍក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន។

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ កិច្ចប្រជុំចង្អៀតនៃប្រមុខមុខងារសាធារណៈអាស៊ានដែលបានធ្វើនៅក្នុងទីក្រុងសាយបឺចាយ៉ា ប្រទេសម៉ាឡេស៊ី បានព្រមព្រៀងគ្នាដើម្បីធ្វើការប្តូរឈ្មោះ ACCSM ទៅជាកិច្ចសហប្រតិបត្តិការអាស៊ានស្តីពីកិច្ចការមុខងារសាធារណៈ ដើម្បីឆ្លុះបញ្ចាំងអំពីកិច្ចសហប្រតិបត្តិការប្រកបដោយនិរន្តរភាពរវាងរដ្ឋសមាជិកអាស៊ានទាំងក្នុងអំឡុងពេល និងចន្លោះពេលកិច្ចប្រជុំ។ កិច្ចប្រជុំ ចង្អៀតក៏បានអនុម័តសេចក្តីថ្លែងការណ៍រួមពុត្រាចាយ៉ាស្តីពីវិស័យអាទិភាពរបស់អាស៊ានក្រោយឆ្នាំ ២០១៥ សំដៅឆ្ពោះទៅរកមុខងារសាធារណៈដែលផ្តោតលើពលរដ្ឋជាស្នូល ត្រូវបានចុះហត្ថលេខាដោយប្រមុខមុខងារសាធារណៈអាស៊ានទាំង១០។

ដូចដែលមានចែងនៅក្នុងលក្ខខណ្ឌយោងរបស់ ACCSM (Terms of Reference of ACCSM) ដែលត្រូវបានអនុម័តដោយកិច្ចប្រជុំប្រមុខងារសាធារណៈសម្រាប់កិច្ចប្រជុំ ACCSM លើកទី១៨ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ACCSM មានបេសកកម្មដូចខាងក្រោម ៖

១. ACCSM ត្រូវចូលរួមចំណែកដល់ការសម្រេចបានលើទស្សនវិស័យអាស៊ាន២០២៥ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការវិស័យមុខងារសាធារណៈនៅក្នុងអាស៊ាន។

២. ACCSM នឹងផ្តល់កិច្ចសហការអាស៊ានក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលវិស័យមុខងារសាធារណៈ គណនេយ្យភាពសាធារណៈ និងអភិបាលកិច្ចល្អ។

៣. ACCSM ស្វះស្វែងដើម្បីធ្វើលើកកម្ពស់ភាពខ្លាំង នៃរដ្ឋសមាជិកអាស៊ានតាមរយៈ៖

- ការលើកកម្ពស់យន្តការដែលមានស្រាប់សម្រាប់បណ្តាញទំនាក់ទំនង ការរៀនសូត្រ និងការចែក រំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមកក្នុងចំណោមសមាជិកអាស៊ាន
- ការលើកកម្ពស់ និងការសម្របសម្រួលដល់ការផ្លាស់ប្តូរនៃឧត្តមានុវត្តន៍ និងនវានុវត្តន៍នៃការគ្រប់គ្រង សាធារណៈផ្សេងៗ ដោយលើកកម្ពស់តួនាទីរបស់មជ្ឈមណ្ឌលធនធានអាស៊ាន (ARCs) ដែលជាអង្គភាពផ្តល់នូវជំនាញការក្នុងវិស័យអាទិភាពទៅតាមសមត្ថភាពប្រទេសនីមួយៗ
- ការបង្កើតការគាំទ្រគំនិតផ្តួចផ្តើមប្រកបដោយការគាំទ្រ ដើម្បីជួយដល់វិស័យមុខងារសាធារណៈអាស៊ានក្នុងការ អភិវឌ្ឍន៍ និងអនុម័តលើការអនុវត្តតាមបែបទំនើប
- ការអនុវត្តកម្មវិធីផ្សេងៗស្តីពីកិច្ចការមុខងារសាធារណៈដោយមានការគាំទ្រ និងជំនួយឧបត្ថម្ភពីដៃគូរសន្ទនាអាស៊ាននានា និងរបៀបវារៈតំបន់ ឬ អន្តរជាតិ។

កិច្ចសហប្រតិបត្តិរបស់ ACCSM ក្នុងពេលកន្លងមកត្រូវបានបង្ហាញឡើងតាមរយៈផែនការការងារ ACCSM រួមមាន ផែនការការងារ ACCSM ឆ្នាំ ២០០៨-២០១៥។ ផែនការការងារ ACCSM ឆ្នាំ ២០១៦-២០២០ នាពេលបច្ចុប្បន្នបានកំណត់គោលដៅក្នុងការកសាង និងរក្សាបាននូវមុខងារសាធារណៈប្រកបដោយគុណផលខ្ពស់ ប្រកបដោយថាមវន្ត និងយកប្រជាពលរដ្ឋជាស្នូលសម្រាប់ប្រជាជននៃអាស៊ាន។ គោលបំណងនៃផែនការការងារ ACCSM ឆ្នាំ ២០១៦-២០២០ មានដូចតទៅ៖

១.ពង្រឹងសមត្ថភាព និងលទ្ធភាពរបស់មុខងារសាធារណៈអាស៊ានដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមកំពុងកើតឡើង និងតម្រូវការរបស់ប្រជាជនតាមរយៈវិធីសាស្ត្រនវានុវត្តន៍ និងកិច្ចសហប្រតិបត្តិការ និង

២. បង្កបរិស្ថានអំណោយផល ពង្រឹងយន្តការនានា និងការចូលរួមរបស់ភាគីពាក់ព័ន្ធសម្រាប់មុខងារ សាធារណៈអាស៊ានដែលឆ្លើយតប បើកចំហរ និងមានលក្ខណៈបទបែន

ផែនការការងារ ACCSM ឆ្នាំ ២០១៦-២០២០ ផ្តោតលើប្រធានបទអាទិភាពចំនួនប្រាំគឺ៖ (១) ការ បង្កើនសមត្ថភាពកម្លាំងពលកម្ម (២) ការកសាងសមត្ថភាពស្ថាប័ន (៣) ការពង្រឹងភាពជាអ្នកដឹកនាំ (៤) ការ ពង្រឹងមជ្ឈមណ្ឌលធនធានអាស៊ាន និង (៥)ការកំណែទម្រង់វិស័យសាធារណៈ។

សមិទ្ធិផលសំខាន់មួយក្នុងចំពោះសមិទ្ធិផលនានារបស់ ACCSM គឺការបង្កើតមជ្ឈមណ្ឌលធនធានអាស៊ាន (ARCs) ដែលត្រូវបានផ្តួចផ្តើមឡើងក្នុងអំឡុងពេលកិច្ចប្រជុំ ACCSM លើកទី៨ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ក្នុងខែមករា ឆ្នាំ១៩៩៥។ ចាប់ផ្តើមពីមជ្ឈមណ្ឌលធនធានអាស៊ានចំនួន៦ ក្នុងឆ្នាំ១៩៩៥ មជ្ឈមណ្ឌលធនធានអាស៊ានបានរីកដុះដាលជាបន្តបន្ទាប់ និងគិតត្រឹមឆ្នាំ ២០១១ ប្រទេសសមាជិក អាស៊ានទាំង១០ បានបង្កើតមជ្ឈមណ្ឌលធនធានអាស៊ាន ដោយផ្តោតលើ

ប្រធានបទជំនាញឯកទេសរបស់ប្រទេសនីមួយៗ (សូមមើល see the ARC Directory as of 2012)។ បន្ថែមលើនេះ ប្រទេសសមាជិកអាស៊ាន បានធ្វើការស្វ័យវាយតម្លៃជាទៀងទាត់ទៅលើមជ្ឈមណ្ឌលធនធានអាស៊ាន របស់ពួកគេ។

ដោយសារតម្រូវការការកសាងសមត្ថភាព និងផលប្រយោជន៍នៃការវិវត្តន៍ឥតឈប់ឈរនៃវិស័យមុខងារសាធារណៈ ប្រទេសសមាជិកអាស៊ានមានបំណងចង់ឱ្យមជ្ឈមណ្ឌលធនធានអាស៊ានធានាបាននូវភាពពាក់ព័ន្ធរបស់ខ្លួន។ ចំណុចនេះនាំឱ្យមានការកែសម្រួលប្រធានបទរបស់មជ្ឈមណ្ឌលធនធានអាស៊ានមួយចំនួនធំនៅចន្លោះឆ្នាំ២០១៥-២០១៩។ គិតត្រឹមខែឧសភា ឆ្នាំ២០១៧ ប្រធានបទរបស់មជ្ឈមណ្ឌលធនធានអាស៊ានគឺ៖

- ការគ្រប់គ្រងសមត្ថភាពមុខងារសាធារណៈ (ប្រទេសប្រ៊ុយណេ ដារូសាឡឹម)
- ការផ្តល់សេវាសាធារណៈ (ប្រទេសកម្ពុជា)
- ក្រុមអ្នកជំនាញការអាស៊ានក្នុងមុខងារសាធារណៈ (ប្រទេសឥណ្ឌូនេស៊ី)
- ការវាយតម្លៃគុណផលមុខងារសាធារណៈ (ប្រទេសឡាវ)
- កិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រសម្រាប់នវានុវត្តន៍វិស័យមុខងារសាធារណៈ (ប្រទេសម៉ាឡេស៊ី)
- ធន្ទៈម្ចាស់ការក្នុងរដ្ឋបាលសាធារណៈ (ប្រទេសមីយ៉ាន់ម៉ា)
- ការវាយតម្លៃ និងការអភិវឌ្ឍស្ថាប័ន (ប្រទេសហ្វីលីពីន)
- អ្នកដឹកនាំអាស៊ានក្នុងកម្មវិធីធនធានមនុស្សយុទ្ធសាស្ត្រ - ការកសាងសេវាសាធារណៈដែល រួចរាល់ជាស្រេចសម្រាប់អនាគត (ប្រទេសសិង្ហបុរី)
- នវានុវត្តន៍ធនធានមនុស្ស (ប្រទេសថៃ)
- ការគ្រប់គ្រងបុគ្គលិក (ប្រទេសវៀតណាម)

ការពង្រីកកិច្ចសហប្រតិបត្តិការរបស់ ACCSM ជាមួយដៃគូសន្ទនាអាស៊ានបានចាប់ផ្តើមក្នុង ឆ្នាំ២០០៨ នៅពេលដែល ACCSM ស្វាគមន៍ចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ (ត្រូវបានស្គាល់ថាជាប្រទេសបូកបី)។ ការចាប់ផ្តើមសន្និសីទអាស៊ានបូកបី ស្តីពីកិច្ចការមុខងារសាធារណៈត្រូវបានប្រារព្ធឡើងក្នុងខែតុលា ឆ្នាំ២០០៩ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ បានព្រមព្រៀងគ្នាកំណត់ប្រធានបទនៃកិច្ចសហប្រតិបត្តិការលើមុខងារសាធារណៈរវាងអាស៊ាន និងប្រទេសបូកបី។ បន្ទាប់មក សេចក្តីថ្លែងការណ៍រួមលួងប្រាបាងលើកិច្ចសហប្រតិបត្តិការមុខងារសាធារណៈ អាស៊ានបូកបី ត្រូវបានអនុម័តដោយសន្និសីទអាស៊ានបូកបីស្តីពីកិច្ចការមុខងារសាធារណៈ លើកទី២ ក្នុងខែតុលា ឆ្នាំ២០០៩ នៅទីក្រុងលួងប្រាបាង សាធារណរដ្ឋប្រជាមានិតឡាវ។

បន្ទាប់ពីនេះមក កិច្ចសហប្រតិបត្តិការជាមួយប្រទេសបូកបីបានពង្រឹងតាមរយៈការអនុវត្តផែនការការងារ ACCSM+3 សម្រាប់ឆ្នាំ ២០១០-២០១៥ និងឆ្នាំ ២០១៦-២០២០។ ផែនការការងារ ACCSM+3 សម្រាប់ឆ្នាំ ២០១៦-២០២០ (The ACCSM+3 Work Plan 2016-2020) គ្របដណ្តប់លើប្រធានបទចំនួន ០៧ ដូចជា៖ (១) អភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក (E-governance); (២)

ការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍធនធានមនុស្ស ; (៣) ផលិតភាពក្នុងវិស័យសាធារណៈ ; (៤) អភិបាលកិច្ចល្អ ; (៥) កំណែទម្រង់វិស័យសាធារណៈ ; (៦) ការកសាងសមត្ថភាពរដ្ឋបាលមូលដ្ឋាន និងកិច្ចសហប្រតិបត្តិការ ; និង (៧) ការស្រាវជ្រាវ និងនវានុវត្តន៍។

ដោយទទួលស្គាល់អំពីតួនាទីយ៉ាងសំខាន់របស់មុខងារសាធារណៈ ក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសហគមន៍អាស៊ាន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣០ ក្នុងខែមេសា ឆ្នាំ២០១៧ ប្រមុខដឹកនាំអាស៊ានបានចុះហត្ថលេខាលើ សេចក្តីថ្លែងការណ៍អាស៊ានស្តីពីតួនាទីមុខងារសាធារណៈជាកាតាលីករក្នុងការសម្រេចអោយបានចក្ខុវិស័យសហគមន៍អាស៊ាន ២០២៥ (ASEAN Declaration on the Role of Civil Service as a Catalyst for Achieving the ASEAN Community Vision 2025)។ សេចក្តីថ្លែងការណ៍បានបង្ហាញអំពីការប្តេជ្ញាចិត្តរបស់ប្រទេសជាសមាជិកអាស៊ាន ក្នុងការជំរុញកិច្ចសហប្រតិបត្តិការមុខងារសាធារណៈ ក្នុងបញ្ហាពាក់ព័ន្ធជាកន្លឹះ ការលើកកម្ពស់ស្តង់ដារវិជ្ជាជីវៈ និង សមត្ថភាពមន្ត្រីរាជការ ការធានាគោលការណ៍អភិបាលកិច្ចល្អ និងការពង្រឹងស្ថាប័នរដ្ឋាភិបាល ការប្រកាន់ភ្ជាប់ និងការការពារសុខុមាលភាពរបស់មន្ត្រីរាជការ និងការពង្រឹងការកសាងសម្ព័ន្ធភាព បណ្តាញទំនាក់ទំនង និងភាពជាដៃគូ ក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ព្រមទាំងដៃគូសន្ទនាអាស៊ាន និងភាគីពាក់ព័ន្ធផ្សេងទៀត។